## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ០២ ខែ មិនា ឆ្នាំ២០១២

## ជប៉ុនផ្តល់ ៩៨,៩០០ ដុល្លារអាមេរិក សម្រាប់គម្រោងសាងសង់អគារសិក្សា



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុននឹងផ្តល់ទឹកប្រាក់សរុបចំនួន ៩៨,៩០០ ដុល្លាអាមេរិក ដល់មន្ទីរអប់រំយុវជន និងកីឡារាជធានីភ្នំពេញសម្រាប់គម្រោងសាងសង់អគារសិក្សានៅសាលាបឋមសិក្សាព្រែកព្នៅ រាជធានីភ្នំពេញ ។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាដោយលោក កាវ៉ាម៉ូរ៉ា ហ៊ីរ៉ុស៊ី ភារធារីស្តីទីស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោក ជា ជាតិ ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ នៅស្ថានទូតជប៉ុន។

ដើម្បីបំពេញនូវកង្វះខាតផ្នែកបន្ទប់សិក្សា មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញនឹងអនុវត្តគម្រោងសាងសង់អគារសិក្សាបេតុងមួយខ្នងមាន៧បន្ទប់ រួមទាំងការបំពាក់បរិក្ខារសិក្សានៅសាលាបឋមសិក្សាព្រែកព្នៅ ស្ថិតក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ។ ជាផ្នែកមួយនៃគម្រោងនេះផងដែរ បន្ទប់ទឹកដែលមាន៨បន្ទប់នឹងត្រូវបានសាងសង់ផងដែរ។ យើងសង្ឃឹមថា សិស្សានុសិស្សជាង១,១០០នាក់នឹងរីករាយជាមួយបរិស្ថាននៃការសិក្សាដែលកាន់តែល្អប្រសើរឡើង។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ ( *ជំនួយគូសាណូណិ*) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជិវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៤៧លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន ៤៦៦គម្រោងនៅទូទាំងប្រទេស។



---

ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ័៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០
អ៊ីមែល: eco.jpn@.pp.mofa.go.jp
គេហទំព័រ: http://www.kh.emb-japan.go.jp